# រាយការណ៍ពីអាកប្បកិរិយាមិនសមរម្យនៅលើយានសាធារណៈដោយប្រើ STOPIT




ប្រសិនបើអ្នកមានអារម្មណ៍គ្មានផាសុកភាព ឬត្រូវគេគំរាមតាមយានសាធារណៈ អ្នកផ្សេងទៀតក៏ធ្លាប់ជួបរឿង

បុគ្គលគ្រប់រូបអាចក្លាយជាជនរងគ្រោះនៃការបំពានផ្លូវភេទ ឬអាកប្បកិរិយាដែលសង្គមស្អប់ខ្ពើមនៅតាមទីសាធារណៈ ដូចជារថភ្លើង រថត្រាំ និងរថយន្តក្រុង។

មនុស្សទាំងឡាយជាញឹកញយគឺមានការរារែកក្នុងការរាយការណ៍រឿងរ៉ាវដែលកើតឡើងទៅកាន់នគរបាលរដ្ឋវិកថូរៀ ប៉ុន្តែប្រសិនបើវាធ្វើឲ្យអ្នកមានអារម្មណ៍ថាគ្មានសុវត្ថិភាពដោយប្រការណាមួយនោះ វាគឺជារឿងធ្ងន់ធ្ងរហើយ ដែលត្រូវតែបញ្ឈប់។

ដើម្បីជួយដោះស្រាយបញ្ហានេះ នគរបាលរដ្ឋវិកថូរៀបានដាក់ឲ្យដំណើរការ STOPIT ៖ ជាខ្សែទូរស័ព្ទផ្ញើសារដែលអាចរាយការណ៍ជា 13 ភាសាភ្លាមៗ ដោយងាយស្រួល និងរក្សាការសម្ងាត់ទាំងស្រុង។

តាមរយៈការរាយការណ៍ពីអាកប្បកិរិយាទាំងនេះ អ្នកជួយនគរបាលក្នុងការកំណត់មុខសញ្ញាជនល្មើស លើកកម្ពស់ការការពារ និងបង្កើតនូវបណ្តាញកាន់តែមានសុវត្ថិភាពសម្រាប់សហគមន៍ទាំងមូល។

## តើ STOPIT មានដំណើរការដូចម្តេច?

STOPIT គឺជាសេវាកម្មមួយដើម្បីរាយការណ៍ពីការបំពានផ្លូវភេទ និងអាកប្បកិរិយាដែលសង្គមស្អប់ខ្ពើមនៅតាមយានសាធារណៈតាមរយៈការផ្ញើសារជាអក្សរ។

បន្ទាប់ពីការផ្ញើសារ STOPIT ទៅកាន់លេខ 0499 455 455 អ្នកផ្ញើសារនឹងទទួលបានតំណភ្ជាប់ដើម្បីផ្តល់ព័ត៌មានលម្អិតបន្ថែមទៀត ដល់ក្រុមនគរបាលពិសេសរដ្ឋវិកថូរៀដែលអាចធ្វើការ ស៊ើបអង្កេតលើបញ្ហានេះ។

**ចូរផ្ញើសារ STOPIT ទៅលេខ 0499 455 455**

VICTORIA State Government

VICTORIA POLICE

ការផ្ញើសារទៅខ្សែទូរស័ព្ទ STOPIT មិនត្រូវបានមើលភ្លាមៗនោះទេ
ហើយប្រសិនបើអ្នកត្រូវការជំនួយពីនគរបាលជាបន្ទាន់ អ្នកត្រូវទូរស័ព្ទទៅកាន់លេខសូន្យបីដង (000)។

## តើអ្វីខ្លះដែលអ្នកអាចរាយការណ៍បាន?

អ្នកអាចរាយការណ៍នូវអាកប្បកិរិយាផ្លូវភេទគ្រប់យ៉ាងដែលគ្មានការស្វាគមន៍
និងសកម្មភាពដែលសង្គមស្អប់ខ្ពើមទាំងឡាយដែលធ្វើឲ្យអ្នកមានអារម្មណ៍៖

- គ្មានផាសុកភាព
- ភ័យខ្លាច
- ឋិតនៅក្នុងការគំរាមកំហែង

អាកប្បកិរិយាទាំងនេះអាចជាកាយវិការ ឬពាក្យសំដី ដោយប្រយោល ឬចំៗតែម្តង។
វាក៏អាចជាសកម្មភាពកើតឡើងហូរហែច្រើនដង ឬ កើតមានតែម្តង។

ឧទាហរណ៍មួយចំនួននៃអាកប្បកិរិយាផ្លូវភេទដែលគ្មានការស្វាគមន៍រួមមាន ៖

- ការតាមឈ្លប ការសម្លឹងមិនដាក់ភ្នែក ឬការដើរតាម
- ការរំខានឌឺដងជាសាធារណៈ និងការពោលដៀមដាមផ្លូវភេទ ឬកាយវិការអាសអាភាស
- ផ្អែកឬផ្ចឹបទៅលើនរណាម្នាក់ ឬការបំពានលើគម្លាតផ្ទាល់ខ្លួន
- ការរំលោភបំពានផ្លូវភេទ

អ្នកក៏អាចរាយការណ៍នូវអាកប្បកិរិយាដែលសង្គមស្អប់ខ្ពើមដទៃទៀតផងដែរមានដូចជា ៖

- អាកប្បកិរិយាគួរឲ្យសង្ស័យ
- អាសអាភាស ប្រកាន់ពូជសាសន៍ ឬភាសា និងអាកប្បកិរិយាបំពានលើអ្នកដទៃ
- ហេតុការណ៍ពាក់ព័ន្ធការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន
- ការធ្វើឲ្យខូចខាតទ្រព្យសម្បត្តិ

## តើអ្វីខ្លះដែលអ្នកមិនអាចរាយការណ៍បាន?

STOPIT ប្រើសម្រាប់តែរាយការណ៍ហេតុការណ៍មិនបន្ទាន់នៅតាមយានសាធារណៈប៉ុណ្ណោះ។

ការផ្ញើសារទៅខ្សែទូរស័ព្ទ STOPIT មិនត្រូវបានមើលភ្លាមៗនោះទេ
ហើយប្រសិនបើអ្នកត្រូវការជំនួយពីនគរបាលជាបន្ទាន់ អ្នកត្រូវទូរស័ព្ទទៅកាន់លេខសូន្យបីដង (000)។

រាយការណ៍តាម STOPIT
មិនដូចគ្នាទៅនឹងការប្តឹងពីបទឧក្រិដ្ឋផ្លូវការដែលតម្រូវឲ្យអ្នកនិយាយទៅកាន់មន្ត្រីនគរបាល
ទៅដល់ការិយាល័យនគរបាល ឬទាក់ទងខ្សែទូរស័ព្ទបញ្ឈប់បទឧក្រិដ្ឋកម្មតាមលេខ
1800 333 000នោះទេ។

ចូរផ្ញើសារ **STOPIT** ទៅលេខ **0499 455 455**

VICTORIA State Government

VICTORIA POLICE

## តើគេប្រើ STOPIT យ៉ាងដូចម្តេច?

ការប្រើប្រាស់ STOPIT មានភាពងាយស្រួល រហ័ស ដែលអាចរាយការណ៍ជា 13ភាសាខុសៗគ្នា ៖

1. ចូរផ្ញើសារ STOPIT ទៅលេខ 0499 455 455
2. អ្នកនឹងទទួលបានតំណភ្ជាប់ទៅនឹងទម្រង់អនឡាញដែលអ្នកអាចរៀបរាប់ពីព័ត៌មានលម្អិតនៃហេតុការណ៍ ដូចជាប្រភេទអាកប្បកិរិយា ពេលវេលា និងកន្លែងកើតហេតុ។
3. បំពេញទម្រង់(form)ដោយផ្តល់ព័ត៌មានទាំងឡាយណាដែលអ្នកចង់ប្រាប់។ អ្នកក៏មានជម្រើសក្នុងការ ដាក់បញ្ចូលរូបថត ឬវីដេអូបានផងដែរ។
4. ចុចបញ្ជូន ហើយរង់ចាំការផ្ញើសារតបបញ្ជាក់ថាបានទទួល។

បន្ទាប់ពីបំពេញទម្រង់ (form) រួចហើយ ក្រុមពិសេស STOPIT ធ្វើការពិនិត្យរបាយការណ៍ ហើយអាចទូរស័ព្ទទៅអ្នកវិញប្រសិនបើគេត្រូវការព័ត៌មានបន្ថែម។

អ្នកអាចរក្សាលេខទូរស័ព្ទ STOPIT ក្នុងករណីដែលអ្នក ឬមនុស្សស្គាល់អ្នក ត្រូវការវានៅថ្ងៃមុខ។ គ្មានរបាយការណ៍ណាខ្លីពេកនោះទេ ហើយយើងនឹងចាត់វិធានការឲ្យបានហ្មត់ចត់នូវរាល់ការរាយការណ៍ទាំងអស់។

## តើការរាយការណ៍នេះមានលក្ខណៈឯកជនទេ?

របាយការណ៍ STOPIT រក្សាការសម្ងាត់ទាំងស្រុង ហើយត្រូវបានប្រើប្រាស់តែក្នុងគោលបំណងជួយ នគរបាលកំណត់អត្តសញ្ញាណជនល្មើសនៅលើយានសាធារណៈប៉ុណ្ណោះ និងធ្វើឲ្យបណ្តាញដឹកជញ្ជូន សាធារណៈកាន់តែមានសុវត្ថិភាពសម្រាប់ពលរដ្ឋគ្រប់រូប។

## សេវាកម្មគាំពារផ្សេងៗ

សេវាគាំពារគឺមានសម្រាប់ជនរងគ្រោះដោយអាកប្បកិរិយាផ្លូវភេទដែលគ្មានការស្វាគមន៍តាម យាន សាធារណៈ សូមមើល police.vic.gov.au/support-resources-sexual-offences-child-abuse.

ចូរផ្ញើសារ **STOPIT** ទៅលេខ **0499 455 455**

VICTORIA State Government

VICTORIA POLICE